# កំណត់ហេតុមហាសន្និបាតសកលលើកទី ១០

# នៃសហព័ន្ធខ្មែរកម្ពុជាក្រោម

## ថ្ងៃទី ២៧ - ២៩ ឧសភា ឆ្នាំ ២០១៦

## ទិវាបោះឆ្នោតជ្រើសរើសគណៈកម្មការនាយក នៃ

## សហព័ន្ធខ្មែរកម្ពុជាក្រោម នីតិកាល ២០១៦-២០២០

## ប្រារព្ធនៅទីក្រុងសាន់ហូសេ្ស រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក

*នៅវត្តខេមររង្សី*, San Jose, CA, *សហរដ្ឋអាមេរិក*

*ថ្ងៃអាទិត្យទី ២៩ ឧសភា ឆ្នាំ ២០១៦*

*កត់ហេតុដោយ ភិក្ខុនាថសីលោ ត្រឹង ថាច់ យុង*

*វេលាម៉ោង ៩:០០*

*បម្រើកម្មវិធីសន្និបាត ដោយ ពិធីករ ថាច់ រឿង និងពិធីការិនី កៀង សាខន ។*

*របៀបវារៈ*

*គោរពទង់ជាតិ*

*គោរពគុណបុព្វវីរសមណៈ បុព្វវីរបុរស*

*ឧទ្ទេសនាមគណៈកម្មការនាយកថ្មីទាំង ៩ រូប ឡើងកាន់អធិបតាសនៈ ។*

ឧទ្ទេសនាមតំណាងទាំង ៣ ផ្នែក គឺផ្នែកតំណាងព្រះសង្ឃ និងផ្នែកតំណាងយុវជន ព្រមទាំងផ្នែកតំណាងស្ត្រី ដែលគណៈកម្មការយក នៃសហព័ន្ធខ្មែរកម្ពុជាក្រោម អាណត្តិកាល ២០១៦-២០២០ ជ្រើសតាំងតាមលក្ខន្តិកៈ ។

តំណាងព្រះសង្ឃរួមមាន ២ ព្រះអង្គ គឺ

ទី ១ ព្រះតេជព្រះគុណ **ថាច់ ទ្រឿង ធីធីធម្មោ** គង់នៅប្រទេសកាណាដា ជាប្រធានសាសនាអន្តរជាតិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។

ទី ២ **ព្រះតេជព្រះគុណ សឺង យ៉ឺងរតនា** គង់នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ជាប្រធាននាយកដ្ឋានព័ត៌មាននៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។

តំណាងស្ត្រីរួមមាន ២ រូប គឺ

ទី ១ **អ្នកស្រី សឺង ធីនិត** នៅរដ្ឋផែនស៊ីវ៉ៃនញ៉ា សហរដ្ឋអាមេរិក ជានាយិកាគណៈកម្មការស្ត្រីខ្មែរក្រោម នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។

ទី ២ **អ្នកស្រីកៀង សុធី** នៅរដ្ឋផ្លរីដាសហរដ្ឋអាមេរិកជាប្រធានគណៈកម្មាធិការយុវជន នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។

របាយការណ៍របស់ **ព្រះតេជព្រះគុណ ថាច់ ទ្រឿង ធីធីធម្មោ** ជុំវិញកិច្ចការសាសនា ។

របាយការណ៍របស់ **លោក សឺង សម្រេច** ជាប្រធានគណៈកម្មការស្រះគូជុំវិញកិច្ចការងារដំណោះស្រាយហេតុការណ៍ស្រះគូដែលត្រូវគោកគាំងរាំងរីង

ស្ងួតហួតហែងបែកក្រហែង ដែលអាចប្រឈមនឹងការបាត់បង់ ។ លោកបានបញ្ជាក់ថា ស្រះគូជារមណីយដ្ឋានផង ជាសម្បត្តិជាតិកាត់ថ្លៃមិនបានរបស់ខ្មែរក្រោមផង ជាបុរាណដ្ឋាន ជាទីតាំងប្រវត្តិសាស្ត្រផង ជាទីតាំងសាសនាផង ជាទីតាំងវប្បធម៌ប្រពៃណីផង ជាសក្ខីកម្មនៃទឹកដីកម្ពុជាក្រោមផង និងជាព្រលឹងជាតិខ្មែរក្រោមផង ។ គូស្រះស្រីឋិតនៅភូមិតាគូ ឃុំសំរោង ស្រុកកំពង់ធំ ខេត្តព្រះត្រពាំង កម្ពុជាក្រោម បើជាឈ្មោះភាសាយួនបច្ចុប្បន្នគឺ ឋិតនៅអនុសង្កាត់ទី ៣ (Khom 3), សង្កាត់ទី ៨ (Phuong 8), ទីក្រុងព្រះត្រពាំង (Thanh pho Tra vinh)។ ទន្ទឹមនឹងនោះលោកសឺន សម្រេចបានប្រកាសសមាសភាពនៃគណៈកម្មការស្រះគូ និងប្រកាសនូវបុព្វហេតុដែលនាំឲ្យកើតមានគណៈកម្មការស្រះគូដែល តែងតាំងដោយលោកអធិបតីនៃសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងពេលថ្មីជាបន្ទាន់ក្រោយពីហេតុការណ៍ស្រះគូរីងគោក ប្រឈមនឹងការបាត់បង់អន្តរាយនូវបេតិកភ័ណ្ឌជាតិ និងជាបុរាណដ្ឋានដែលមានអាយុកាលពាន់ឆ្នាំមួយនេះ ។ លោកថ្លែងថាគណៈកម្មការនេះបង្កើតឡើងក្នុងគោលបំណង ៣ យ៉ាងគឺ

ទី ១ រកដំណោះស្រាយដោយសន្តិវិធី ស្របតាមសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាតិស្តីអំពីសិទ្ធិជនជាតិដើមត្រង់មាត្រាទី ១១ ដែលចែងថា "ជនជាតិដើមភាគតិចមានសិទ្ធិប្រតិបត្តិ និងធ្វើឲ្យរស់ឡើងវិញនូវប្រពៃណី និងទំនៀមទម្លាប់វប្បធម៌របស់ខ្លួន រួមទាំងសិទ្ធិក្នុងការការពារថែរក្សាស្តារពង្រឹងពង្រីក និងអភិវឌ្ឍន៍ នូវអត្តសញ្ញាណវប្បធម៌ជាតិរបស់ខ្លួន ដែលមានតាំងពីបុរាណកាលរៀងមក ដល់បច្ចុប្បន្ន និងទៅអនាគត ដូចជាតំបន់បុរាណដ្ឋាន

បុរាណវត្ថុ ទីតាំងប្រវត្តិសាស្ត្រ ក្បាច់រចនា បច្ចេកវិទ្យា ពិធីកម្ម សិប្បកម្ម របាំ គំនូរ អក្សរសិល្ប៍ អក្សរសាស្ត្រ" ។ ទន្ទឹមនឹងនោះមាត្រាទី ១២ ក៏មានចែងបន្ថែមទៀតថា "ជនជាតិដើមភាគតិច មានសិទ្ធិពេញលេញក្នុងការអភិរក្ស និងអភិវឌ្ឍន៍ផ្សព្វផ្សាយនូវប្រពៃណីទំនៀមទម្លាប់ ពិធីកម្មផ្សេងៗ នូវជំនឿសាសនា" ។

ទី ២ គឺធ្វើការស្រាវជ្រាវកត់ត្រាប្រវត្តិស្រះគូឡើងបន្ថែមដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ ។

ទី ៣ ប្រមូលឯកសារដាក់ស្នើទៅអង្គ UNESCO សូមឲ្យដាក់ស្រះគូចូល ក្នុងបេតិកភ័ណ្ឌពិភពលោក ជាសម្បត្តិវប្បធម៌មនុស្សជាតិ ។

របាយការណ៍របស់ **ព្រះតេជព្រះគុណ យឿង តាព** ជាអតីតប្រធានសម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម ។

របាយការណ៍របស់ **លោក ត្រឹង សារុង** ជាប្រធានសាខាសហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអឺរ៉ុប ។

របាយការណ៍របស់ **លោក ឃួន ណាកា** អំពីការគម្រោងការកសាងមជ្ឈមណ្ឌលវប្បធម៌ខ្មែរក្រោម របស់សហព័ន្ធខ្មែរកម្ពុជាក្រោម នៅប្រទេសបារាំងជាប់ព្រំដែនប្រទេសស្វិស ដើម្បីផ្សព្វផ្សាយវប្បធម៌ និង ជាការងាយស្រួលដល់សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងការធ្វើដំណើរទៅចូលរួមកិច្ចប្រជុំណាមួយជាប់ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និង សិទ្ធិស្ត្រីជាដើមនៅទីសំណាក់ការអង្គការសហប្រជាជាតិនៅទីក្រុងសឺណែវប្រទេសស្វិស ។

***លោក ថាច់ សេ*** *ប្រធានសភាតំណាង ប្រកាសសមាសភាពនៃគណៈកម្ម-ការនាយកអាណត្តិកាល ២០១៦-២០២០ ទាំង ១៣ អង្គ និង រូបដូចតទៅ*

*ក. គណៈកម្មការនាយកជាប់ឆ្នោត មានចំនួន ៩ រូបគឺ*

| | |
|---|---|
| *ទី ១ លោក ថាច់ វឿន* | *ជាអធិបតី ។* |
| *ទី ២ លោក ចៅ វៀប* | *ជាប្រធានសភាព្រឹទ្ធាចារ្យ ។* |
| *ទី ៣ លោក ថាច់ សេ* | *ជាប្រធានសភាតំណាង ។* |
| *ទី ៤ លោក ថាច់ ង៉ុក ថាច់* | *ជាប្រធានប្រតិបត្តិ ។* |
| *ទី ៥ លោក ប្រាក់ សិរីវុឌ្ឍី* | *ជាអនុប្រធានទី ១ ។* |
| *ទី ៦ លោក ម៉ៅ មុនី* | *ជាអនុប្រធានទី ២ ។* |
| *ទី ៧ លោក ត្រឹង ម៉ាន់រិទ្ធ* | *ជានាយកផែនការ ។* |
| *ទី ៨ លោក សឺង ហួ* | *ជាអគ្គលេខាធិការ ។* |
| *ទី ៩ លោក ត្រឹង យ៉ាប* | *ជានាយករដ្ឋបាល ។* |

*ខ. គណៈកម្មការនាយកជ្រើសតាំង ដោយគណៈកម្មការនាយកជាប់ឆ្នោតមាន ៤ អង្គនិងរូបគឺ*

| | |
|---|---|
| *ទី ១០ អ្នកស្រី សឺង ធីនិត* | *ជានាយិកាគណៈកម្មការស្ត្រី ។* |

*ទី ១១ អ្នកស្រី គៀង សុធី ជាប្រធានគណៈកម្មាធិការយុវជនខ្មែរកម្ពុជាក្រោម ។*

*ទី ១២ **ព្រះតេជព្រះគុណ ថាច់ ទ្រឿង ធីធីធម្មោ** ជាប្រធានគណៈកម្មការសាសនាអន្តរជាតិនៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។*

*ទី ១៣ **ព្រះតេជព្រះគុណ សឺង យ៉ឺងរតនា** ជាប្រធានគណៈកម្មការសាសនាអន្តរជាតិ និង ជាប្រធាននាយកដ្ឋានព័ត៌មាននៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។*

*សមាសភាពគណៈកម្មការនាយកនៃសហព័ន្ធខ្មែរកម្ពុជាក្រោមអាណត្តិ-កាល ២០១៦-២០២០ ជាភាសាអង់គ្លេសដូចខាងក្រោម*

Members of the Board of Directors

May 29, 2016

| Name | Title |
|---|---|
| Thach Vien | Chairman of the Board of Directors |
| Chau Riep | President of Senior Council |
| Thach Xe | Chair of the House of Representatives |
| Thach Ngoc Thach | President |

| | |
|---|---|
| Prak Sereivuth | First Vice President |
| Mau Moni | Second Vice President |
| Tran Mannrinh | Director of Planning |
| Son Hua | Secretary General |
| Tran Giap | Chief of Administration |
| Son Thi Nith | Director of Women Affairs |
| Kien Sothy | President of the KKF Youth Committee |
| Venerable TT Dhammo | Commissioner of International Religious Affairs |
| Ven Son Yoeng Ratana | Director of the KKF Media |

*លោក **អធិបតី ថាច់ វឿន** សំដែងសោមនស្សរកថា តំណាងសហព័ន្ធខ្មែរកម្ពុជាក្រោមថ្លែងអំណរគុណ ចំពោះគណៈកម្មការរៀបចំមហាសន្និបាតសកល លើកទី ១០ បោះឆ្នោតជ្រើសរើសគណៈកម្មការនាយកនៃសហព័ន្ធខ្មែរកម្ពុជាក្រោម អាណត្តិកាល ២០១៦-២០២០ ដែលបានធ្វើឡើងនៅថ្ងៃទី ២៧-*

២៩ ឧសភា ឆ្នាំ ២០១៦ នាទីក្រុងសាន់ហូសេ្ស រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។

គណៈកម្មការនាយកអាណត្តិថ្មីឱទ្ទេសនាមអ្នកស្រីកៀង សុធី ឲ្យប្រកាសអជ្ឍត្តិកច្បាប់ (ច្បាប់បញ្ញាផ្ទៃក្នុង) នៃសហព័ន្ធខ្មែរកម្ពុជាក្រោមជាភាសាអង់គ្លេស បកប្រែជាភាសាខ្មែរដោយលោកប្រាក់សិរីវុឌ្ឍី ជាអនុប្រធានទី ១ ទទួលបន្ទុកកិច្ចការបរទេស ។

បន្ទាប់មកជានាទីគណៈកម្មកានាយក និងអង្គមហាសន្និបាតពិភាក្សាគ្នាជុំវិញការអនុម័តិអជ្ឍត្តិកច្បាប់នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ។

ក្រោយអំពីកិច្ចពិភាក្សាគ្នាយ៉ាងលម្អិត អំពីបញ្ហាច្បាប់និងផែនការជាតិផែនការអន្តរជាតិរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមនៅពេលខាងមុខ អស់ពេលប្រមាណជិត ២ ម៉ោង ក៏មានការឯកភាពគ្នាជាផ្លុងមួយ ។

**អ្នកស្រី កៀង សាខន** ជាពិធីការិនីមហាសន្និបាត និងជានិពន្ធនាយិកាផលិតកម្មខ្មែរក្រោម បានច្រៀងចម្រៀងអំណរគុណមហាសន្និបាតមួយបទដែលជាស្នាដៃនិពន្ធថ្មីរបស់អ្នកស្រីផ្ទាល់ យ៉ាងពីរោះពិសាជាទីគាប់ចិត្តនៃសន្និបាតជន ។

អង្គមហាសន្និបាតថតរូបជុំគ្នាទុកជាឯកសារ ។

មុននឹងបញ្ចប់មហាសន្និបាត ព្រះសង្ឃស្វាធ្យាយជយន្តោជាសិទ្ធជយ-មង្គលកម្មជូនទីមហាសន្និបាតជាកិច្ចបិទមហាសន្និបាតសកលលើកទី ១០ ។

*ជយោមហាសន្និបាតសកលលើកទី ១០*

*មហាសន្និបាតសម្រេចដោគជ័យយ៉ាងត្រចះត្រចង់*

*មហាសន្និបាតចប់ដោយបរិបូណ៌ នៅវេលាម៉ោង ៣:៤៥ នាទី ។*

*ហត្ថលេខា* *ហត្ថលេខា*

**ថាច់ ទៀន** **ភិក្ខុ នាថសីលោ ត្រឹង ថាច់ យុង**

*អធិបតីមហាសន្និបាត* *លេខាធិការមហាសន្និបាត*